ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៦០៤ ក្រ២ស
-ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩
-សំណុំរឿងព្រហ្មទណ្ឌលេខ ២២៣
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៩
-សំណុំរឿងស៊ើបសួរលេខ ១០៨
ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩
-សំណុំរឿងជំនុំជម្រះ ១៤៩១
ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩

តាចនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ៨:00 នាទី នៅសាលសវនាការទី២ ដោយមានសមាសភាព៖

ក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រីអនុប្រធាន [redacted] ជាប្រធានក្រុមប្រឹក្សា
-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា
-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២២៣ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

- ឈ្មោះ [redacted] **វណ្ណា** ភេទប្រុស អាយុ៣៥ឆ្នាំ កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត[redacted] ខេត្តស្វាយរៀង ទីលំនៅមុនពេលឃាត់ខ្លួន មិនពិតប្រាកដ ឪពុកឈ្មោះ[redacted] យ៉ង់ (ស្លាប់) ម្តាយឈ្មោះ [redacted] យន់ (ស្លាប់) ប្រពន្ធឈ្មោះ ស្រីតឿ គ្មានកូន ទោសពីមុនគ្មាន ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

ដីកាបង្គាប់ឃុំខ្លួនលេខ ៣៨៣ "ច១" ដឃដ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

ជាប់ចោទពីបទ **ហិង្សាដោយចេតនា ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចច្រកចូលខឿងហែម មុខផ្ទះលេខ១៥Eo ផ្លូវលេខ១២០ ភូមិ២ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ។

- បានឃើញរបាយការណ៍សំយោគលេខ **០០២/១៩ របក** ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ របស់អធិការនគរបាលខណ្ឌដូនពេញ ។

Scanned with CamScanner

- បានឃើញដីកាសន្និដ្ឋានស្តាពរលេខ **១៣៥៩ អ.ឃ.ក** ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩ របស់អយ្យអមការសាលាដំបូងរាជធានីភ្នំពេញ ។

- បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ **១៨១២ ច១.ឧ.ដ** ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ ៖

កាលពីថ្ងៃទី១០-០១-២០១៩ វេលាម៉ោង ១៦:៤០នាទី មានករណី **ហិង្សាដោយចេតនាស្តានទម្ងន់ទោសដោយសារមរណភាពជនរងគ្រោះ** មួយកើតឡើងនៅចំណុចក្នុងច្រកឱឿងហែម មុខផ្ទះលេខ១៥Eo ផ្លូវលេខ១២០ ភូមិ២ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលបង្កឡើងដោយឈ្មោះ [redacted]**វណ្ណា** ភេទប្រុស អាយុ៣៥ឆ្នាំ បានឈ្លោះប្រកែកគ្នាជាមួយជនរងគ្រោះ ឈ្មោះ [redacted]**វណ្ណារ៉ា** ភេទប្រុស អាយុ២៨ឆ្នាំ រួចឈ្មោះ [redacted]**វណ្ណា** បានយកដំបងឈើវាយទៅលើជនរងគ្រោះបណ្តាលឱ្យរបួសធ្ងន់ ហើយក៏បានស្លាប់នៅពេលបញ្ជូនទៅមន្ទីរពេទ្យ ។

ឆាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] **វណ្ណា** បានឆ្លើយថា៖ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង១៦ និង៤០នាទី ខ្លួនបានទៅទិញបារី តម្លៃ១០០០រៀល នៅបេនឡាន ក៏មានបក្សពួករបស់ជនរងគ្រោះកំពុងផឹកមានគ្នាពាក់ បានហៅខ្លួនសួរកលុយខ្លួន ២០០០០ម៉ឺនរៀល ទិញគ្រឿងញៀនជក់ ហើយខ្លួនក៏ប្រាប់ថាអត់មានទេ ពួកគេក៏ឆែកឆេរឃើញទូរសព្ទរបស់ខ្លួន ក៏បានយកទៅខ្លួនបានទាមទារមកវិញតែគេមិនឱ្យ គេក៏យកដំបងវាយខ្លួន ខ្លួនរងជាប់បានបោះដំបងទៅរកគេវិញ តែខ្លួនមិនបានដឹងថាត្រូវអ្នកណាទេ ។ ប្រហែលជា ២ម៉ោងក្រោយមកខ្លួនក៏ត្រឡប់មកបេនឡានវិញ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

- អំណានចម្លើយដើមបណ្តឹងឈ្មោះ [redacted] **សាង៉ម** បានឆ្លើយថា ៖ ខ្លួនបានទទួលពត៌មានតាមទូរសព្ទពីប៉ុស្តិ៍នគរបាលរដ្ឋបាលថា កូនប្រុសរបស់ខ្លួនឈ្មោះ [redacted] **វណ្ណារ៉ា** ត្រូវបានឈ្មោះ [redacted] **វណ្ណា** យកឈើមូលវាយចំផ្នែកមុខ បណ្តាលឱ្យរបួសធ្ងន់ បន្ទាប់ពីបញ្ជូនទៅមន្ទីរពេទ្យកាល់ម៉ែត កូនប្រុសរបស់ខ្លួនក៏បានស្លាប់បាត់ ។

- អំណានកំណត់ហេតុទទួលវត្ថុចាប់ឃកមាន ដំបងឈើមូលប្រវែងប្រហែល ៧៥ក ។

សេចក្តីសន្និដ្ឋានឬសុំរបស់តំណាងអយ្យការ

ក្រោយពីបានធ្វើការសួរដេញដោលលើជនជាប់ចោទឈ្មោះ [redacted] **វណ្ណា** ស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] **សាង៉ម** ឃើញថាពិតជាបានប្រព្រឹត្តអំពើ **ហិង្សាដោយចេតនា ស្តានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចច្រក ចូលឱឿងហែម មុខផ្ទះលេខ១៥Eo ផ្លូវលេខ១២០ ភូមិ២ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែ មករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ២២៥ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តដោយឈ្មោះ [redacted]**វណ្ណា** ប្រាកដមែន ។ តំណាងអយ្យការ សុំតម្កល់បទចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្តាពរ ។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

- មេធាវីការពារសិទ្ធឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ៖ កូនក្តីរបស់ខ្លួនគ្មានគំនិតចង់ឱ្យជនរងគ្រោះស្លាប់នោះទេ ហើយក៏មិនបានដឹងថាជនរងគ្រោះស្លាប់ដែរ ហើយមិនបានគេចវេសក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ ខ្លួនសំណូមពរសុំឱ្យតុលាការផ្តល់នូវស្ថានសម្រាលឱ្យដល់កូនក្តីខ្លួនផង ។

សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted]**វណ្ណា** សំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោស ។

Scanned with CamScanner

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានពិនិត្យ និងពិចារណាតាមច្បាប់រួចហើយ

សំអាងហេតុ

១- តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **១៨១២ "ច១"ដដ** ចុះថ្ងៃទី២២-៤-២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនជនជាប់ចោទឈ្មោះ [redacted]**វណ្ណា** ភេទប្រុស អាយុ៣៥ឆ្នាំ ពីបទ **ហិង្សាដោយចេតនា ស្តានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចច្រក ចូលឌឿងហែម មុខផ្ទះលេខ ១៥Eo ផ្លូវលេខ១២០ ភូមិ២ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែ មករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ មកតុលាការជំនុំជម្រះ ។

២- តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]**វណ្ណា** អះអាងថាខ្លួនបានគ្រវែងកំណាត់ឈើទៅលើជនរងគ្រោះដោយសារតែសកម្មភាពការពារខ្លួន ទប់ទល់ទៅលើការព្រួតវាយរបស់បក្សពួកជនរងគ្រោះមានគ្នាដល់ទៅ ០៣នាក់ តែប៉ុណ្ណោះ ពេលនោះស្ថានភាពងងឹត ខ្លួនមិនបានដឹងថា ជនរងគ្រោះត្រូវរបួសត្រង់ណាទេ ក្រោយកើតហេតុប្រហែល ២ ម៉ោង សមត្ថកិច្ចក៏បានឃាត់ខ្លួនរហូតមកដល់សព្វថ្ងៃ ។ ចម្លើយនេះគ្រាន់តែជាចម្លើយដោះសារយករួចខ្លួនប៉ុណ្ណោះ មិនមានឯកសារ ឬសក្ខីតាងណាមួយមកបញ្ជាក់ឲ្យតុលាការជឿបានឡើយ ។

៣- តាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted]**សាង៉ម** ថា ៖ ខ្លួនបានទទួលពត៌មានតាមទូរសព្ទពីប៉ុស្តិ៍នគរបាលរដ្ឋបាលថា កូនរបស់ខ្លួនឈ្មោ[redacted]**វណ្ណារ៉ា** ត្រូវបានឈ្មោះ [redacted]**ណ្ណា** យកឈើម្ជុលវាយចំផ្នែមុខ បណ្តាលឲ្យរបួសធ្ងន់ បន្ទាប់ពីបញ្ជូនទៅមន្ទីរពេទ្យកាល់ម៉ែត កូនប្រុសរបស់ខ្លួនក៏បានស្លាប់បាត់ ។

៤- តាមកំណត់ហេតុប្រគល់សាកសព ឈ្មោះ[redacted]**វណ្ណារ៉ា** លេខ ០១៩/១៩ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ របស់ការិយាល័យនគរបាលបច្ចេកទេសវិទ្យាសាស្ត្រ បានសន្និដ្ឋានថា សពស្លាប់ដោយសារប៉ះទង្គិចក្បាលធ្ងន់ធ្ងរ ។

៥- អំពើរបស់ជនជាប់ចោទបានប្រព្រឹត្តជាអំពើ **ហិង្សាដោយចេតនាមានស្តានទម្ងន់ទោស ដោយសារមរណភាពនៃជនរងគ្រោះ** ដែលច្បាប់បានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ។

៦- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ឈ្មោះ[redacted]**វណ្ណា** ភេទប្រុស អាយុ៣៥ឆ្នាំ

ពីបទ **ហិង្សាដោយចេតនាស្តានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចច្រកចូលឌឿងហែម មុខផ្ទះលេខ១៥Eo ផ្លូវលេខ១២០ ភូមិ២ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ។

៧- តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ក្រោយពីបានធ្វើការសួរដេញដោលលើជនជាប់ចោទឈ្មោះ [redacted]**វណ្ណា** ស្តាប់អំណានចម្លើយរបស់ដើមបណ្តឹង ឈ្មោះ [redacted]**សាង៉ម** ឃើញថាពិតជាបានប្រព្រឹត្តអំពើ **ហិង្សាដោយចេតនាស្តានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចច្រក ចូលឌឿងហែម មុខផ្ទះលេខ១៥Eo ផ្លូវលេខ១២០

ភូមិ២ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែ មករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តដោយឈ្មោះ [redacted] វណ្ណា ប្រាកដមែន ។ តំណាងអយ្យការសុំតម្កល់បទចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្តាពរ តុលាការបានពិចារណារួចហើយ ។

៨- តាមសេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានសន្និដ្ឋានថា កូនក្តីរបស់ខ្លួនគ្មានគំនិតចង់ឲ្យជនរងគ្រោះស្លាប់នោះទេ ហើយក៏មិនបានដឹងថាជនរងគ្រោះស្លាប់ដែរ ហើយមិនបានគេចវេសក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ ខ្លួនសំណូមពរសុំឲ្យតុលាការផ្តល់នូវស្ថានសម្រាលឲ្យដល់កូនក្តីខ្លួនផង ។ តុលាការបានពិចារណារួចហើយ ។

៩- តាមសម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា បានស្នើសុំឲ្យតុលាការបន្ធូរបន្ថយទោស យើងបានពិចារណារួចហើយ ។

១០- ឈ្មោះ [redacted] សាង៉ម មិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ក៏ដូចជាក្នុងដំណាក់កាលជំនុំជម្រះឡើយ គប្បីតុលាការមិនលើកយកមកពិចារណា និងសម្រេចឡើយ ។

១១- វត្ថុចាប់យកមាន ដំបងមួលប្រវែងប្រហែល ៧តឹក គប្បីតុលាការសម្រេចរឹបអូសបំផ្លាញចោល តាមមាត្រា ៦២, ៦៣ នៃក្រមព្រហ្មទណ្ឌ ។

ហេតុផ្តួចផ្តើមសម្រេច

១- ផ្តន្ទាទោស ៖

ឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់កំណត់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួនបណ្តោះអាសន្ន ។

ពីបទ **ហិង្សាដោយចេតនាស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចច្រកចូលខឿងហែម មុខផ្ទះលេខ១៥Eo ផ្លូវលេខ១២០ ភូមិ២ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែ មករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ។

២- រឹបអូសវត្ថុចាប់យកមាន ដំបងមួលប្រវែងប្រហែល ៧តឹក បំផ្លាញចោល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វណ្ណា និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជី	ចៅក្រមប្រឹក្សា	ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា	ហត្ថលេខា និងត្រា
[redacted]		

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បត្តិ៍ ៨កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩

ក្រឡាបញ្ជី

[redacted]

ជាន់ឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]